ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

- លេខ : ២៧១/០០៩/២០១៧
  ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៧២/០១០/២០១៧
  ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៧៣/០១១/២០១៧
  ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៧

**សេចក្តីសម្រេច**

លេខ : ១៦៣/០០៣/២០១៧ កបធ.ច
ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០១៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្តីសម្រេចលេខ ០០២/១៧ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចឃុំគ្រែងគ្រយឹង ទុកជាបានការពេញទាំងមូល
- បានឃើញសេចក្តីសម្រេចលេខ ០១៦ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្តីសម្រេចលេខ ០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចសង្កាត់ចោមចៅ ទុកជាបានការពេញទាំងមូល

- បានឃើញសេចក្តីសម្រេចលេខ ០១៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្តីសម្រេចលេខ ០០១/១៧ ០០៣/១៧ និង ០០៤/១៧ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចឃុំត្រែងត្រយឹង ទុកជាបានការពេញទាំងមូល
- បានឃើញលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់លោក **អេង សំអាង** ជូនលោកស្រីមេធាវី **ម៉េង សុភារី** ដើម្បីធ្វើជាមេធាវីតំណាងក្នុងការប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ និងសេចក្តីសម្រេចលេខ ០១៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់លោក **សរ ណាល់** ជូនលោកស្រីមេធាវី **ម៉េង សុភារី** ដើម្បីធ្វើជាមេធាវីតំណាងក្នុងការប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១៦ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់លោកស្រីមេធាវី **ម៉េង សុភារី** តំណាងឲ្យឈ្មោះ **អេង សំអាង** និងឈ្មោះ **សរ ណាល់** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១៥ សេចក្តីសម្រេចលេខ ០១៦ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ និងសេចក្តីសម្រេចលេខ ០១៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោកស្រីមេធាវី **ម៉េង សុភារី** កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៨០ គ.ជ.ប ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **ឌុច សុន** និងឯកឧត្តម **សោម សូរីដា** មកបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ លើពាក្យបណ្តឹងរបស់លោកស្រីមេធាវី **ម៉េង សុភារី**
- បានឃើញកំណត់ហេតុបំភ្លឺរបស់ឯកឧត្តម **ឌុច សុន** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ភ្ជាប់ដោយសារណាចំនួន ០៣ ច្បាប់ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ និងឯកសារពាក់ព័ន្ធនឹងប្រជាពលរដ្ឋចំនួន ១៤ នាក់ ដែលត្រូវបានប្តឹងថាជាជនជាតិបរទេស (វៀតណាម)
- បានឃើញកំណត់ហេតុចុះស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧ នៅឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ និងនៅសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
- បានឃើញលិខិតលេខ ១២១ គ.ជ.ប ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **សោម សូរីដា** និងលោក **ហួត បូរិន** ចូលរួមសវនាការជាសាធារណៈ ដើម្បីបំភ្លឺលើពាក្យបណ្តឹងរបស់លោកស្រីមេធាវី **ម៉េង សុភារី**